ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៨១ សប្តាហ៍ទី ១ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់ថ្លៃជាមុន)

348.033
CAM

មាតិកា

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

១.ព្រះរាជក្រម

១៩-១០-២០០៧ -ព្រះរាជក្រម នស/រកម/១០០៧/០២៧ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ ស្តីពីសម្បទាន ៨៨៧៦

២.ព្រះរាជក្រឹត្យ

០៣-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៤៩៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គីម អ៊ីមព្យូ** (KIM IMPYO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម អរុណ** (KIM AK ROUN) ៨៩០០

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥១៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លាវ ម៉ានកាម** (LAU MAN KAM) ជនជាតិចិន កើតនៅខេត្តហ៊្វូចៀន ប្រទេសចិន ដោយប្តូរឈ្មោះជា **លាវ យ៉ុងឆៀន** (LAU YUNG CHIN) ៨៩០១

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥១៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ម៉េតស្យូ រ៉េនដល** (MATTHEW NICHOLAS RENDALL) ជនជាតិអូស្ត្រាលី សញ្ជាតិអូស្ត្រាលី កើតនៅចក្រភព អង់គ្លេស ៨៩០២

២៤-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥២៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ ជូនចំពោះនាយទាហានជាន់ខ្ពស់ចំនួន ១៨ រូប ៨៩០៣

២៤-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥២៦ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ មាស ,ថ្នាក់ប្រាក់ និងថ្នាក់សំរិទ្ធ ចំពោះនាយទាហាន ជាន់ខ្ពស់ និងនាយទាហាន ចំនួន ៥៩៩ រូប ៨៩០៥

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

០១-១១-២០០៧ -អនុក្រឹត្យលេខ ១៦០ អនក្រ.បក ស្តីពីការធ្វើអនុបយោគ ទីតាំងមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ក្រុងព្រះសីហនុ និង ទីតាំងដីមួយផ្នែក របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តរតនគិរី ៨៥២៤

០១-១១-២០០៧ -អនុក្រឹត្យលេខ ១៦១ អនក្រ.បក ស្តីពីការធ្វើអនុបយោគ ទីតាំងកោះស្រមោច កោះប្រឹស កោះក្របី និងកោះគ្រែះ ៨៥២៦

០២-១១-២០០៧ -អនុក្រឹត្យលេខ ១៦២ អនក្រ.បកស្តីពីការផ្ទេរឥណទានថវិកា ៨៥២៨

០២-១១-២០០៧ -អនុក្រឹត្យលេខ ១៦៣ អនក្រ.បកស្តីពីការផ្ទេរឥណទានថវិកា ៨៥៣០

២២-១០-២០០៧ -អនុក្រឹត្យលេខ ៨៧១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៥៣២

២៣-១០-២០០៧ -អនុក្រឹត្យលេខ ៨៧២ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ៨៥៥៨

២៣-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ៨៥៥៩

២៣-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៤ អនក្រ.តត ស្តីពីការដាក់ឱ្យនាយនគរបាលជាតិចូលនិវត្តន៍ ៨៥៦០

២៣-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៥៦១

២៤-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៦២

២៤-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៥៦៣

២៤-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីសង្ឃ ៨៥៦៤

២៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៧៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៥៦៥

២.សេចក្តីសំរេច

៣០-១០-២០០៧ -សេចក្តីសំរេចលេខ ៥៧ សសរ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះនៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ៨៥៧៣

០២-១១-២០០៧ -សេចក្តីសំរេចលេខ ៥៨ សសរ ស្តីពីការបង្កើតគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ ៨៥៧៧

III-ភាគទារបណ្ណាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៧-១០-២០០៧ -ប្រកាសលេខ ១០៤៨ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូ ហាន់សៃ បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ខេមបូ ហាន់សៃ " ៨៩៧៩

២៣-១០-២០០៧ -ប្រកាសលេខ ១០៥៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ដានស៊ី ស៊ីបផ្លាយ(ខេមបូឌា) លីមីធីត បង្កើតរោងចក្រ " ផលិតស្បែកជើងគ្រប់ប្រភេទ " ដែលមានឈ្មោះថា " ដានស៊ី ស៊ីបផ្លាយ(ខេមបូឌា) លីមីធីត " ៨៩៨១

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ណាធី ខេមបូ ឌីវេឡុបមេន** ៨៩៨៣

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រាយ៉ា ខូ អិលធីឌី** ៨៩៨៥

១៣-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **និល តៅ** ៨៩៨៧

១៤-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហៀប-សេង ហ៊ីន ខូអិលធីឌី** ៨៩៨៩

១៤-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ុំ ស៊ុំ ទីន** ៨៩៩១

១៤-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេន ហ្វារម៉ា អិលធីឌី** ៨៩៩៣

១៤-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ ហ៊ុំម៉ូសា ត្រេឌីង** ៨៩៩៥

១៤-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេនស៊ំ ខនស្ត្រាក់សិន (ខេមបូឌា) តឺធីអ៊ី អិលធីឌី** ៨៩៩៧

ព្រះរាជក្រម

នស/រកម/១០០៧/០២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសម្បទាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

សម្បទាន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយហិរញ្ញប្បទានឯកជននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបំរើផលប្រយោជន៍សាធារណៈ និងបំពេញសេចក្តីត្រូវការរបស់សង្គម និងសេដ្ឋកិច្ចជាតិ ។

មាត្រា ២.-

ច្បាប់នេះមានវិសាលភាពគ្រប់គ្រងសម្បទានទាំងឡាយ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

សម្បទានត្រូវផ្តល់តាមរយៈកិច្ចសន្យាសម្បទាន ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

មាត្រា ៣.-

វាក្យសព្ទសំខាន់ៗនៅក្នុងច្បាប់នេះមានន័យដូចខាងក្រោម :

- **ការអនុញ្ញាត** សំដៅដល់ការអនុញ្ញាត ការជម្រះបញ្ជី ការយល់ព្រម ការផ្តល់អាជ្ញាប័ណ្ណ ការផ្តល់លិខិតអនុញ្ញាត ឬ ការចុះបញ្ជីនានា ដែលត្រូវទទួលយកពីស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តគម្រោងសម្បទានដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ។

- **សម្បទាន** សំដៅដល់ទង្វើណាមួយជារបស់រដ្ឋ ដែលស្ថាប័នមានសមត្ថកិច្ចផ្តល់ទង្វើនោះ ទៅឱ្យឯកជននូវផ្នែកណាមួយឬទាំងស្រុងនៃការអនុវត្តគម្រោងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធណាមួយដែលជាធម្មតាស្ថាប័នមានសមត្ថកិច្ចនោះ ជាអ្នកទទួលខុសត្រូវ ហើយដែលឯកជននោះ ទទួលភារកិច្ចមួយផ្នែកធំលើការសាងសង់ និង/ឬហានិភ័យ ឬ ទទួលបាននូវផលចំណេញ តាមរយៈការទូទាត់សងវិញពីរដ្ឋាភិបាលនូវប្រាក់ចំណូល ឬ កម្រៃ និងការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

យកថ្លៃឈ្នួល ដែលបានប្រមូលយកពីអ្នកប្រើប្រាស់ ឬ ពីអតិថិជន ។ ទង្វើរបស់រដ្ឋទាំងនោះ ចាប់ពីពេលនេះតទៅនឹងត្រូវកំណត់ថា“សម្បទាន”នៅក្រោមច្បាប់នេះ ដោយមិនគិតពីឈ្មោះស្របច្បាប់ដែលបានប្រើប្រាស់សម្រាប់ទង្វើនោះឡើយ ។

- **សម្បទានិក** សំដៅដល់បុគ្គលដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមកិច្ចសន្យាសម្បទាន ដែលបានធ្វើជាមួយស្ថាប័នជាប់កិច្ចសន្យា ។

- **កិច្ចសន្យាសម្បទាន** សំដៅដល់កិច្ចព្រមព្រៀងដែលភ្ជាប់កាតព្វកិច្ចទៅវិញទៅមក រវាងស្ថាប័នជាប់កិច្ចសន្យាជាមួយសម្បទានិក ក្នុងនោះមានការកំណត់ពីគោលការណ៍និងលក្ខខណ្ឌសម្រាប់អនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ។

- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

- **គម្រោងសម្បទាន** សំដៅដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមការផ្តល់សម្បទានណាមួយ ។

- **ស្ថាប័នជាប់កិច្ចសន្យា** សំដៅដល់ស្ថាប័នមានសមត្ថកិច្ចដែលមានសិទ្ធិចុះកិច្ចសន្យាសម្បទាន ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ ។

- **សំណង់ហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់សំណង់ជារូបវ័ន្តនិងប្រព័ន្ធដែលផ្តល់សេវាកម្មដោយផ្ទាល់ ឬ ដោយប្រយោលដល់សាធារណជនទូទៅ ។

- **គម្រោងហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់គំនូរប្លង់ ការសាងសង់ ការថែទាំ ឬ ការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធថ្មី ឬ ការធ្វើទំនើបកម្មរូបនីយកម្ម ការធ្វើនីតិសម្បទាការពង្រីក ការគ្រប់គ្រង ឬ ការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ។

- **គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សំដៅដល់គម្រោងវិនិយោគដែលទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយអនុលោមទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៤.-

ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ដែលមានភារកិច្ចទទួលធ្វើគម្រោងហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះរួមមាន ក្រសួង ស្ថាប័នសាធារណៈ នីតិបុគ្គលរបស់រដ្ឋ អាជ្ញាធរមូលដ្ឋាន ដែលបានទទួលប្រតិភូកម្មនូវអំណាចដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិចុះកិច្ចសន្យាសម្បទានលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន និងមានសិទ្ធិចុះកិច្ចព្រមព្រៀងពាក់ព័ន្ធបន្ទាប់បន្សំ រួមទាំងកិច្ចព្រមព្រៀងដែលមានគោលបំណងសម្រួលការងារហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ និងបទប្បញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងអនុក្រឹត្យ ។

មាត្រា ៥.-

កិច្ចសន្យាសម្បទាន ដែលមានទំនាក់ទំនងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់សេវា ដោយផ្ទាល់ឬដោយប្រយោល ដើម្បីជាប្រយោជន៍សាធារណៈត្រូវបានចូលរួមដោយស្ថាប័នពាក់ព័ន្ធលើវិស័យដូចតទៅ :

ក-ការផលិត ការបញ្ជូន និងការចែកចាយ ថាមពលអគ្គិសនី ។

ខ-ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក ។

គ-ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។

ឃ-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន ។

ង-ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារៈ បម្រើឱ្យគម្រោងផ្នែកទេសចរណ៍មានជាអាទិ៍ រមណីយដ្ឋានទេសចរណ៍ សារមន្ទីរ ។

ច-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យវិស័យឧស្ម័ននិងប្រេង មានជាអាទិ៍ បំពង់បង្ហូរប្រេង ទីស្តុកប្រេង ។

ឆ-ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ ។

ជ-ប្រព្រឹត្តិកម្ម និងការគ្រប់គ្រងសំណល់ ។

ឈ-ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំនិង វិស័យកីឡា ។

ញ-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅឋានសង្គម ។

ដ-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យប្រព័ន្ធធារាសាស្ត្រ និងការងារកសិកម្ម ។

ឋ-វិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយអនុញ្ញាតឱ្យមានការផ្តល់ នូវសម្បទាន ។

មាត្រា ៦.-

កិច្ចសន្យាសម្បទាន អាចអនុវត្តតាមទម្រង់ដូចខាងក្រោម :

-សាងសង់ អាជីវកម្ម និងផ្ទេរ

-សាងសង់ ជួល និងផ្ទេរ

-សាងសង់ ផ្ទេរ និងអាជីវកម្ម

-សាងសង់ ធ្វើម្ចាស់ និងអាជីវកម្ម

-សាងសង់ ធ្វើម្ចាស់ អាជីវកម្ម និងផ្ទេរ

-សាងសង់ សហការ និងផ្ទេរ

-ពង្រីក អាជីវកម្ម និងផ្ទេរ

-ទំនើបភាវូបនីយកម្ម អាជីវកម្ម និងផ្ទេរ

-ទំនើបភាវូបនីយកម្ម ធ្វើម្ចាស់ និងអាជីវកម្ម

-ជួល និងអាជីវកម្ម គ្រប់គ្រង ឬ កិច្ចព្រមព្រៀងគ្រប់គ្រង ឬ ជម្រើសដទៃទៀតនៃ ទម្រង់ទាំងនោះ ឬ ទម្រង់ប្រហាក់ប្រហែល ដោយរួមបញ្ចូលទាំងការអនុវត្តសំណង់ហេដ្ឋា-រចនាសម្ព័ន្ធនៃសម្ព័ន្ធអាជីវកម្មរួមរវាងសាធារណៈ និងឯកជន ។

មាត្រា ៧.-

កិច្ចសន្យាសម្បទានណាមួយអាចត្រូវចាប់ផ្តើមធ្វើបាន លុះត្រាតែគម្រោងហេដ្ឋារចនា-សម្ព័ន្ធនោះ ត្រូវបានអនុម័តជាមុនថាជាគម្រោងសម្បទានស្របតាមនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យ ។

ជំពូកទី ២
ការសម្របសម្រួលផ្នែករដ្ឋបាល និងសេវាកម្ម

មាត្រា ៨.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាស្ថាប័នច្រកចេញ-ចូលតែមួយ សម្រាប់ទទួលការអនុញ្ញាតដែលជាតម្រូវការចាំបាច់ ក្នុងការអនុវត្តគម្រោងវិនិយោគស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។ បន្ទាប់ពីបានទទួលការស្នើសុំអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមកិច្ចសន្យាសម្បទានពីសម្បទានិក ដែលជ្រើសរើសឱ្យអនុវត្តគម្រោង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវ :

ក-ផ្តល់ជូននូវការលើកទឹកចិត្តដល់សម្បទានិកដោយអនុលោមទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

ខ-ធ្វើការបញ្ជាក់អំពីការអនុញ្ញាតទាំងឡាយដែលត្រូវទទួលបាន សម្រាប់គម្រោងសម្បទានពីស្ថាប័នមានសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាត ។

គ-ទទួលយកឱ្យទាន់ពេលវេលានូវរាល់លិខិតអនុញ្ញាត ដែលបានចែងក្នុងមាត្រានេះពីស្ថាប័នពាក់ព័ន្ធជំនួសមុខឱ្យសម្បទានិក នៅពេលដែលព័ត៌មាននិងឯកសារចាំបាច់ទាំងឡាយត្រូវបានផ្តល់គ្រប់ចំនួនពីសម្បទានិក ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវកំណត់រយៈពេលមួយ សម្រាប់ស្ថាប័នទទួលខុសត្រូវក្នុងការផ្តល់លិខិតអនុញ្ញាតលើគម្រោងសម្បទាន លើកលែងតែមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីស្ថាប័ននេះ នៅមុនរយៈពេលនៃការកំណត់នោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ៩.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នសេវាកម្មប្រមូលផ្តុំក្នុងការផ្តល់ព័ត៌មានទូទៅតាមការស្នើពីអ្នកវិនិយោគដែលចង់វិនិយោគក្នុងគម្រោងសម្បទាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលទាំងព័ត៌មានដូចមានចែងក្នុងមាត្រា ៨ ចំណុច ក និង ខ នៃច្បាប់នេះ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវផ្តល់ជូនអ្នកវិនិយោគដែលមានសក្តានុពលនានានូវការថតចម្លងឯកសារច្បាប់ និងបទប្បញ្ញត្តិផ្សេងៗស្តីអំពីការដាក់ពាក្យសុំជាទូទៅនៃគម្រោងសម្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១០.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានភារកិច្ច៖

ក-ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលកម្ពុជា អំពីបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយសម្បទាន និង ផ្តល់អនុសាសន៍ ដើម្បីកែលំអឱ្យកាន់តែប្រសើរឡើងនូវច្បាប់នឹងបទប្បញ្ញត្តិទាំងឡាយសម្រាប់អនុវត្តគម្រោងសម្បទាន

ខ-ជួយដល់ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ក្នុងការធ្វើអត្តសញ្ញាណកម្មនិងវាយតម្លៃលើកាលានុវត្តភាពនានា សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលឯកជនធ្វើហិរញ្ញប្បទាន ព្រមទាំងជួយផ្សព្វផ្សាយដល់សហគមន៍អ្នកវិនិយោគនូវគម្រោងទាំងឡាយណាដែលអាចដំណើរការបាន

គ-បង្កើននូវភាពជំនាញចាំបាច់ក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ជួយវាយតម្លៃពីខាងក្រៅ ដើម្បីជួយស្ថាប័នជាប់កិច្ចសន្យាក្នុងការរៀបចំការដេញថ្លៃ និងការត្រួតពិនិត្យគម្រោងសម្បទានដែលស្មុគស្មាញ

ឃ-លើកការស្នើអំពីនីតិវិធីធ្វើការជ្រើសរើសគំរូ និងគំរូឯកសារសម្រាប់ធ្វើគម្រោងដើម្បីធ្វើសនិទានកម្មលើការធ្វើហិរញ្ញប្បទានការអនុវត្ត និងការត្រួតពិនិត្យគម្រោងសម្បទាន

ង-សម្របសម្រួលក្នុងការកសាងសមត្ថភាព និងការបណ្តុះបណ្តាលដល់មន្ត្រីរាជការដែលធ្វើការងារពាក់ព័ន្ធនឹងការងារសម្បទាន

ច-រក្សាទុកនូវបញ្ជីស្តីពីកិច្ចសន្យាសម្បទាន និងរាល់ឯកសារនៃគម្រោងសម្បទាន ដើម្បីទុកឱ្យស្ថាប័នជាប់កិច្ចសន្យាធ្វើការវាយតម្លៃ និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ។

ជំពូកទី ៣
ការជ្រើសរើស និងការរៀបចំសម្បទានិក

មាត្រា ១១.-

ស្ថាប័នជាប់កិច្ចសន្យា ត្រូវធ្វើការជ្រើសរើសសម្បទានិក តាមវិធីដេញថ្លៃជាលក្ខណៈជាតិ ឬ អន្តរជាតិ ឬ តាមនីតិវិធីចរចា ដោយផ្អែកទៅតាមកាលៈទេសៈ ។

នីតិវិធីនៃការជ្រើសរើសសម្បទានិកនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

មាត្រា ១២.-

នៅពេលដែលដំណើរការជ្រើសរើសសម្បទានិកត្រូវបានបំពេញសព្វគ្រប់ ហើយស្ថាប័នជាប់កិច្ចសន្យាក៏បានត្រៀមក្នុងការទទួលពាក្យដេញថ្លៃចុងក្រោយ ឬ ការស្នើចរចាហើយនោះ ស្ថាប័នជាប់កិច្ចសន្យាត្រូវតែទទួលបាននូវការអនុម័តជាគោលការណ៍សម្រាប់លក្ខខណ្ឌចុងក្រោយនៃកិច្ចសន្យាសម្បទាន តាមការតម្រូវនិងស្របតាមនីតិវិធីដែលនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ប្រសិនបើការពិនិត្យឡើងវិញនូវកិច្ចសន្យាសម្បទានដែលបានរៀបចំស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះធ្វើឱ្យបេក្ខជនដែលបានជ្រើសរើសតាមនីតិវិធីត្រឹមត្រូវ ហើយរងនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន បេក្ខជននោះអាចដកពាក្យដេញថ្លៃ ឬ ការស្នើរបស់ខ្លួនដោយមិនទទួលរងនូវការបាត់បង់ប្រាក់តម្កល់សម្រាប់ធានាការដេញថ្លៃឡើយ ។

មាត្រា ១៣.-

បន្ទាប់ពីបានទទួលការអនុម័តយល់ព្រមដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ស្ថាប័នជាប់កិច្ចសន្យាត្រូវចេញសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទានទៅបេក្ខជនដែលបានជ្រើសរើស មុននឹងអនុវត្តការចុះកិច្ចសន្យាសម្បទាននេះ ។

ស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក ត្រូវចុះហត្ថលេខាលើកិច្ចសន្យាសម្បទានក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹងស្តីពីការផ្តល់សម្បទាន ។

រយៈពេលនេះអាចពន្យារបាន ប្រសិនបើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងស្ថាប័នជាប់កិច្ចសន្យានិងសម្បទានិក ។ ការខកខានរបស់ស្ថាប័នជាប់កិច្ចសន្យាក្នុងការអនុវត្តស្របតាមមាត្រា ១៣ កថាខ័ណ្ឌទី ២ នៃច្បាប់នេះនឹងអាចឱ្យសម្បទានិកមានសិទ្ធិក្នុងការដកពាក្យដេញថ្លៃ ឬ ដកការស្នើរចរ ដោយមិនទទួលរងនូវការបាត់បង់ប្រាក់តម្កល់សម្រាប់ធានាការដេញថ្លៃឡើយ ។

មាត្រា ១៤.-

ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទាន សម្បទានិកត្រូវតែបង្កើតដោយស្របរាន់ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានូវនីតិបុគ្គលមួយ ដែលនឹងអនុវត្តគម្រោងសម្បទាននិងដាក់ពាក្យសុំជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥.-

លើកលែងតែមានការតម្រូវដោយបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ដទៃទៀត ភាគីជាប់កិច្ចសន្យាត្រូវកំណត់ក្នុងកិច្ចសន្យាសម្បទាននូវករណីដូចខាងក្រោម :

ក-ប្រភេទ វិសាលភាព បរិមាណការងារដែលត្រូវបំពេញ និងសេវាកម្មដែលត្រូវផ្តល់ដោយសម្បទានិក ។

ខ-ការលើកទឹកចិត្តដែលត្រូវផ្តល់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការចំណាយ បង្កើនល្បឿននៃការសាងសង់ និងបង្កើនគុណភាពនៃកិច្ចដំណើរការនិងការថែទាំដើម្បីជាប្រយោជន៍សាធារណៈ ។

គ-រាល់កម្រៃថ្លៃបង់ការប្រើប្រាស់ ថ្លៃឈ្នួលជួល ឬ ចំណាយផ្សេងៗ ដែលត្រូវដាក់ដោយសម្បទានិកអនុវត្ត ត្រូវតែបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឃ-ការព្រមព្រៀងលើការទទួលយកហានិភ័យរៀងៗខ្លួន ឬ ការព្រមព្រៀងពីការទទួលយកហានិភ័យរួមគ្នា ។

ង-ការកម្រិតសេវាកម្ម និងបមាណដែលតម្រូវឱ្យសម្បទានិកអនុវត្តនៅក្នុងប្រតិបត្តិការនិងការគ្រប់គ្រងសំណង់ហេដ្ឋារចនាសម្ព័ន្ធ និងផលវិបាកនៃការមិនអនុវត្តស្របតាមកម្រិតសេវាកម្មនិងបមាណដែលបានកំណត់ ។

ច-យន្តការបង់ប្រាក់ ។

ឆ-ការប្តេជ្ញាចិត្ត និងកិច្ចសហប្រតិបត្តិការរបស់ស្ថាប័នជាប់កិច្ចសន្យា និងស្ថាប័នអានសមត្ថកិច្ចផ្សេងទៀត ក្នុងការគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងអំឡុងពេលសម្បទាន ។

ជ-ករណីផ្សេងៗទៀត ប្រសិនបើភាគីទាំងពីរយល់ថាសមស្រប ។

មាត្រា ១៦.-

សម្បទានិកត្រូវអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រងរាល់ហានិភ័យ ហើយមិនត្រូវពឹងផ្អែកលើការសុំឥណទាន ឬ ការធានាពីស្ថាប័នជាប់កិច្ចសន្យាឡើយ ។ ក្នុងកាលៈទេសៈពិសេស ការធានាអាចត្រូវផ្តល់បាន តែការធានានោះត្រូវអនុវត្តស្របទៅនឹងនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ។

មាត្រា ១៧.-

ដោយអនុលោមតាមការដាក់កំហិតណាមួយ ដែលមានចែងក្នុងកិច្ចសន្យាសម្បទាន ឬមាននៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សម្បទានិកមានសិទ្ធិបង្កើតសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិ សិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួន រួមបញ្ចូលនូវអ្វីទាំងឡាយដែលពាក់ព័ន្ធនៅក្នុងគម្រោងសម្បទាន ដើម្បីធានានូវរាល់ហិរញ្ញប្បទានដែលត្រូវការ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាសម្បទាន ម្ចាស់ភាគហ៊ុននៃសម្បទានិកមានសិទ្ធិធ្វើការអះអាង ឬ បង្កើតសិទ្ធិប្រាតិភោគនៅក្នុងភាគហ៊ុនរបស់ខ្លួនជាសម្បទានិក ដើម្បីធានានូវរាល់ហិរញ្ញប្បទានដែលត្រូវការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ។

មាត្រា ១៨.-

នៅពេលដែលមានការរំលោភធ្ងន់ធ្ងរពីសំណាក់សម្បទានិក ឬ ដោយហេតុការណ៍ណាមួយដែលជាមូលហេតុនាំឱ្យមានការបញ្ចប់កិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាអាចយល់ព្រមជាមួយស្ថាប័នដែលផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយដាក់ជំនួសសម្បទានិកដោយបុគ្គលថ្មី ដើម្បីចាត់តាំងឱ្យធ្វើកិច្ចការតាមកិច្ចសន្យាសម្បទានដែលមានស្រាប់ ស្របតាមលក្ខខណ្ឌនិងនីតិវិធីដែលបានព្រមព្រៀងគ្នាជាមុន រវាងស្ថាប័នជាប់កិច្ចសន្យាជាមួយស្ថាប័នដែលជាអ្នកផ្តល់ហិរញ្ញប្បទាននោះ ។

មាត្រា ១៩.-

សិទ្ធិ និងកាតព្វកិច្ចរបស់សម្បទានិកដែលមានចែងក្នុងកិច្ចសន្យាសម្បទាន មិនអាចផ្ទេរទៅតតិយជនបានទេ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីស្ថាប័នជាប់កិច្ចសន្យា ។

ការគ្រប់គ្រងផលប្រយោជន៍របស់សម្បទានិក ដែលមានចែងនៅក្នុងកិច្ចសន្យាសម្បទាន មិនអាចផ្ទេរទៅតតិយជនបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីស្ថាប័នជាប់កិច្ចសន្យា លើកលែងតែចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ដែលបានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។

មាត្រា ២០.-

លើកលែងតែមានការចែងនៅក្នុងកិច្ចសន្យាសម្បទានច្បាស់លាស់ សម្បទានិកត្រូវទទួលខុសត្រូវលើគំនូរប្លង់និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រងរាល់ហានិភ័យ ។ គំនូរប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធត្រូវតែស្របជាមួយនឹងច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ។ កិច្ចសន្យាសម្បទានអាចតម្រូវឱ្យមានអ្នកជំនាញការឯករាជ្យ ដើម្បីធ្វើរបាយការណ៍ជូនស្ថាប័នជាប់កិច្ចសន្យាលើករណីផ្សេងៗ ពាក់ព័ន្ធទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

មាត្រា ២១.–

លើកលែងតែមានចែងនៅក្នុងកិច្ចសន្យាសម្បទានច្បាស់លាស់ សម្បទានិកត្រូវធ្វើអាជីវកម្ម និងថែរក្សាសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដោយសាមីខ្លួនទទួលបន្ទុកការចំណាយទាំងអស់ និងរ៉ាប់រងរាល់ហានិភ័យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ។

លើកលែងតែមានចែងនៅក្នុងកិច្ចសន្យាសម្បទាន សម្បទានិកត្រូវធានានូវនិរន្តរភាពក្នុងការផ្តល់សេវាកម្ម ។ ដូចដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាមានសិទ្ធិកាន់កាប់ការងារអាជីវកម្មនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធជាបណ្តោះអាសន្ន ដើម្បីធានានូវប្រសិទ្ធិភាពនៃការផ្តល់សេវាកម្មដោយគ្មានរអាក់រអួល ក្នុងករណីសម្បទានិកមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន តែតម្រូវឱ្យស្ថាប័នជាប់កិច្ចសន្យាធ្វើការជូនដំណឹងដល់សម្បទានិក ដើម្បីធ្វើការកែតម្រូវការខកខានមិនបានអនុវត្តក្នុងរយៈពេលនោះ ដូចមានចែងនៅក្នុងកិច្ចសន្យាសម្បទាន ឬ ប្រសិនបើពុំមានចែងទេ គឺត្រូវធ្វើក្នុងពេលសមស្របណាមួយ ។

មាត្រា ២២.–

ដើម្បីធានាការអនុវត្តដោយសម្បទានិកនូវកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចសន្យាសម្បទាន និងដោយផ្អែកតាមតម្រូវការនៃកិច្ចសន្យា សម្បទានិកត្រូវតម្កល់ប្រាក់ធានាការអនុវត្តកិច្ចសន្យាឱ្យបានពេញលេញសម្រាប់ដំណាក់កាលជាកំណត់នៃគម្រោងសម្បទានជូនស្ថាប័នជាប់កិច្ចសន្យា និងទៅតាមទម្រង់ ពេលវេលា និង បរិមាណ ដែលមានចែងនៅក្នុងកិច្ចសន្យាសម្បទាន ។

មាត្រា ២៣.–

កិច្ចសន្យាសម្បទានអាចផ្តល់កាលានុវត្តភាពឱ្យសហគ្រាស និងស្ថាប័នស្រាវជ្រាវក្នុងស្រុកមានលទ្ធភាពចូលរួមនៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យាកម្មន្តសាល ឬ សកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដោយសហប្រតិបត្តិការជាមួយសម្បទានិក ។ សហប្រតិបត្តិការដែលអាចនាំមកនូវប្រាក់ចំណូលបន្ថែមដល់សម្បទានិក ត្រូវតែផ្តល់ឱ្យសហគ្រាស និងស្ថាប័នរដ្ឋឯកជនក្នុងស្រុកនូវឱកាសដ៏ពិតៗ ដើម្បីទទួលបាននូវការបញ្ជាទិញ ការផ្គត់ផ្គង់ទំនិញ ការផ្តល់សេវាកម្ម

ក្នុងស្រុក និងក្រៅប្រទេស ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍបច្ចេកវិទ្យាពាក់ព័ន្ធទៅនឹងសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ ។

នៅពេលដែលធ្វើការវាយតម្លៃឯកសារដេញថ្លៃ ស្ថាប័នជាប់កិច្ចសន្យាអាចគិតគូរដល់សក្តានុពលទូលំទូលាយនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ដែលលើកឡើងដោយអ្នកដេញថ្លៃ ហើយដែលអាចកំណត់ជាលក្ខណៈវិនិច្ឆ័យនៅក្នុងសេចក្តីជូនដំណឹងអំពីការដេញថ្លៃទាក់ទងទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ។

មាត្រា ២៤.-

កិច្ចសន្យាសម្បទានត្រូវគ្រប់គ្រងដោយច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រសិនបើពុំមានច្បាប់ ឬ បទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ចែងអំពីករណីដែលពាក់ព័ន្ធនោះទេ បទប្បញ្ញត្តិនៃកិច្ចសន្យាសម្បទាន ត្រូវគ្រប់គ្រងដោយច្បាប់ដែលជ្រើសរើសដោយភាគីជាប់កិច្ចសន្យា ហើយដែលច្បាប់នោះមិនមានភាពផ្ទុយគ្នាទៅនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

សម្បទានិកមានសិទ្ធិក្នុងការជ្រើសរើសច្បាប់គ្រប់គ្រងនៃកិច្ចព្រមព្រៀងបន្ទាប់បន្សំទាក់ទងនឹងការអនុវត្តគម្រោងសម្បទាន ។

មាត្រា ២៥.-

នៅពេលណាដែលកិច្ចសន្យាសម្បទានបានតម្រូវឱ្យសម្បទានិកផ្ទេរ នៅពេលបញ្ចប់គម្រោងសម្បទាននូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធជូនដល់ស្ថាប័នជាប់កិច្ចសន្យា ឬ អ្នកដែលទទួលបានការតែងតាំង ការផ្ទេរនោះ ត្រូវស្របទៅនឹងពេលវេលាដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។

សំណង់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវផ្ទេរនោះ ត្រូវមានលក្ខណៈល្អស្របទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន និងត្រូវបានជម្រះឱ្យបានជ្រះស្រឡះនូវរាល់បំណុល បន្ទុក សិទ្ធិប្រាតិភោគ និងការតវ៉ាទាមទារនានា ។

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

មាត្រា ៣២.-

រាល់សកម្មភាពដែលទាក់ទងនឹងការអនុវត្តច្បាប់នេះ ត្រូវអនុវត្តឱ្យស្របទៅនឹងតម្រូវការនៃបមាណីសុខភាពនិងសុវត្ថិភាពនិងការងារបរិស្ថាន ដោយសម្បទានិកត្រូវថែរក្សាគ្រប់ពេលវេលានូវផែនការជាយថាហេតុនេះ ដើម្បីទប់ទល់នឹងគ្រោះថ្នាក់ និងភាពអាសន្នបន្ទាន់ ដែលអាចនាំឱ្យបាត់បង់ជីវិត ឬ របួស ការពុល ឬ ការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដែលតម្រូវឱ្យមានដោយច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជានិងកិច្ចសន្យាសម្បទាន ។

មាត្រា ៣៣.-

ក្នុងករណីដែលសំណង់ហេដ្ឋារចនាសម្ព័ន្ធ ត្រូវផ្ទេរជូនស្ថាប័នមានសមត្ថកិច្ច នៅពេលបញ្ចប់កិច្ចសន្យាសម្បទាន សម្បទានិកត្រូវផ្តល់នូវការបណ្តុះបណ្តាលជូនជនកម្ពុជា ដើម្បីអ្នកទាំងនោះអាចទទួលរ៉ាប់រងជំនួសនៅគ្រប់កម្រិត ក្នុងការធ្វើអាជីវកម្មនិងថែទាំសំណង់ហេដ្ឋារចនាសម្ព័ន្ធនោះជាបន្ត ។ កិច្ចការទាំងនេះត្រូវធ្វើនៅមុនពេលផុតកំណត់នៃរយៈពេលសម្បទានបាន ស្របទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងជាមួយស្ថាប័នជាប់កិច្ចសន្យានៅក្នុងកិច្ចសន្យាសម្បទាន ។

មាត្រា ៣៤.-

ពាក់ព័ន្ធនឹងសកម្មភាពដែលទាក់ទងនឹងការអនុវត្តច្បាប់នេះ បុគ្គលសញ្ជាតិខ្មែរដែលចូលរួមប្រកួតប្រជែងការងារផ្គត់ផ្គង់ អាចត្រូវបានផ្តល់នូវកាលានុវត្តភាពពិតប្រាកដ ដើម្បីទទួលបាននូវការបញ្ជាទិញសម្រាប់ការសាងសង់ ការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ។

មាត្រា ៣៥.-

កិច្ចសន្យាសម្បទានមិនត្រូវបង្កើតនូវឯកាធិភាពឬបង្កើតនូវសិទ្ធិផ្តាច់មុខឡើយ ។ ប៉ុន្តែដើម្បីជាផលប្រយោជន៍សាធារណៈ សិទ្ធិផ្តាច់មុខអាចបញ្ចូលបានក្នុងកិច្ចសន្យាសម្បទានដែលនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៣៦.-

សម្បទានិកត្រូវធានាថា ជនណាដែលធ្វើការ ឬ ផ្តល់សេវាឱ្យខ្លួន ដោយផ្ទាល់ក្តី ឬតាមរយៈនិយោជិតក្តី ឬ តាមរយៈអ្នកទទួលម៉ៅការក្តី ឬ អ្នកម៉ៅការបន្តក្តីត្រូវតែបំពេញកិច្ចការ ស្របទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

ប្រសិនបើមានការខូចខាតដល់តតិយជន បង្កឡើងដោយជនណាម្នាក់ដែលធ្វើកិច្ចការឱ្យសម្បទានិកហើយតម្រូវឱ្យមានសំណង សម្បទានិកនិងអ្នកប្រព្រឹត្ត ត្រូវទទួលខុសត្រូវទូទាត់សំណងនោះតាមការទទួលខុសត្រូវរួមគ្នា និងទីទៃពីគ្នា ។

ជំពូកទី ៤
ការបញ្ចប់អាណត្តិនៃសម្បទាន

មាត្រា ៣៧.-

កិច្ចសន្យាសម្បទាន ត្រូវបញ្ជាក់អំពីរយៈពេលសម្បទាន ដែលមិនត្រូវលើសពី ៣០ (សាមសិប) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាសម្បទាន ដោយផ្អែកតាមមាត្រា ១៣ នៃច្បាប់នេះ ។ ក្នុងករណីចាំបាច់ ដោយយោងទៅលើប្រភេទនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាអាចកំណត់រយៈពេលសម្បទានវែងជាងនេះ ។

រយៈពេលសម្បទាន ដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទាន មិនអាចពន្យារបានឡើយ លើកលែងតែជាលទ្ធផលដែលចេញមកពីស្ថានភាពដូចខាងក្រោម ៖

១-ពន្យារដើម្បីបង្គ្រប់ពេលការងារ ឬ ការបង្អាក់ដំណើរការដោយមូលហេតុនៃការរំលោភកិច្ចសន្យាដោយស្ថាប័នជាប់កិច្ចសន្យា ឬ ដោយទង្វើនៃស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។

២-ពន្យារដើម្បីបង្គ្រប់ពេលការងារ ឬ ការបង្អាក់ដំណើរការដោយហេតុការណ៍ប្រធានសក្តិ ដូចដែលមានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន ហើយដែលនាំឱ្យសម្បទានិកមិនអាចមានលទ្ធភាពបំពេញបានមកវិញនូវការចំណាយ ឬ ការខាតបង់ដែលបានបណ្តាលមកពីស្ថានភាពខាងលើ ដូចអ្នកផ្តល់ការធានារ៉ាប់រងលើគម្រោងសម្រាប់រយៈពេលសម្បទានដំបូង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

រយៈពេលសម្បទានដូចមានចែងនៅក្នុងកិច្ចសន្យាសម្បទាន អាចត្រូវបន្តបាន ដើម្បីអនុញ្ញាតឱ្យសម្បទានិកអាចស្តារចំណាយបន្ថែមដែលកើតឡើងដោយសារមានលក្ខខណ្ឌថ្មីៗរបស់ស្ថាប័នជាប់កិច្ចសន្យាដែលពុំបានគិតទុកជាមុននៅក្នុងកិច្ចសន្យាសម្បទាន ប្រសិនបើសម្បទានិកពុំអាចស្តារឡើងវិញបាននូវចំណាយទាំងនោះនៅក្នុងរយៈពេលសម្បទានដែលបានចែង ។

មាត្រា ៣៨.-

កិច្ចសន្យាសម្បទានត្រូវបញ្ជាក់ ដោយមានភាពសមស្របអំពីលក្ខខណ្ឌដែលផ្តល់សិទ្ធិឱ្យភាគីមួយអាចបញ្ចប់កិច្ចសន្យាមុនថ្ងៃផុតកំណត់នៃរយៈពេលសម្បទាន ព្រមទាំងបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចនៃភាគីជាប់កិច្ចសន្យា ប្រសិនបើមានការបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ។ ប្រសិនបើមានបញ្ជាក់ក្នុងកិច្ចសន្យាសម្បទាន ករណីប្រធានសក្តិអាចនាំឱ្យភាគីមួយមានសិទ្ធិបញ្ចប់កិច្ចសន្យាសម្បទានបាន ។

ក្នុងករណីដែលការបញ្ចប់កិច្ចសន្យាបណ្តាលមកពីការរំលោភធ្ងន់ធ្ងរ ដោយស្ថាប័នជាប់កិច្ចសន្យា ឬ ដោយស្ថាប័នមានសមត្ថកិច្ចដទៃទៀតលើកាតព្វកិច្ចទាក់ទងទៅនឹងគម្រោងសម្បទាន សម្បទានិកមានសិទ្ធិទទួលបាននូវការប៉ះប៉ូវសំណង ដោយអនុលោមទៅតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាសម្បទាន រួមបញ្ចូលទាំងតម្លៃត្រឹមត្រូវនៃការងារដែលបានធ្វើការចំណាយដែលមាន ឬការខាតបង់ដែលទទួលរងដោយសម្បទានិក រួមទាំងការខាតបង់ប្រាក់ចំណេញដែលមានភាពសមស្រប ។

មាត្រា ៣៩.-

វិវាទរវាងស្ថាប័នជាប់កិច្ចសន្យានិងសម្បទានិក ត្រូវដោះស្រាយដោយអនុលោមទៅតាមយន្តការដោះស្រាយវិវាទដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទាន ដោយរាប់បញ្ចូលទាំងការដោះស្រាយតាមរយៈមជ្ឈត្តករអន្តរជាតិ ប្រសិនបើមានការព្រមព្រៀងរបស់គូភាគី ។

សេចក្តីសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច ឬ ដោយមជ្ឈត្តករស្របទៅតាមមាត្រានេះ ត្រូវមានសុពលភាព និងត្រូវអនុវត្តដោយស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិក អនុលោមទៅតាមខ្លឹមសារនៃសេចក្តីសម្រេចនោះ ។

មាត្រា ៤០.-

ស្ថាប័នជាប់កិច្ចសន្យាជាអ្នកទទួលខុសត្រូវដើម្បីធានាថា កិច្ចសន្យាសម្បទានត្រូវអនុវត្តដោយត្រឹមត្រូវ និងត្រូវបង្កើតនូវយន្តការព្រមទាំងនីតិវិធីសម្រាប់ត្រួតពិនិត្យសម្របសម្រួលការអនុវត្ត និងដំណើរការនៃកិច្ចសន្យាសម្បទាន ហើយរាយការណ៍ស្តីពីការគ្រប់គ្រងកិច្ចសន្យាសម្បទាន ក្នុងរបាយការណ៍ថវិកាប្រចាំឆ្នាំនៃស្ថាប័នជាប់កិច្ចសន្យា ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬក្រសួងពាក់ព័ន្ធដែលទទួលខុសត្រូវ ។

មាត្រា ៤១.-

មុននឹងឈានដល់ការព្រមព្រៀងធ្វើការកែសម្រួលកិច្ចសន្យាសម្បទាន ស្ថាប័នជាប់កិច្ចសន្យាត្រូវតែទទួលបាននូវការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នមានសមត្ថកិច្ចដែលបានចូលរួមអនុម័តកិច្ចសន្យាសម្បទានដំបូង ។

នីតិវិធីនៃការកែសម្រួលនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ជំពូកទី ៥

ទោសប្បញ្ញត្តិ

មាត្រា ៤២.-

រូបវន្តបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលរងទណ្ឌកម្មតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។

អ្នកសមគំនិតត្រូវទទួលទោសដូចចារីដែរ ។

នីតិបុគ្គលត្រូវទទួលខុសត្រូវ និង ទទួលទណ្ឌកម្មពិន័យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះជាធរមាន ប្រសិនបើនិយោជិត ភ្នាក់ងារ ឬ បុគ្គលិករបស់ខ្លួនដែលធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃការងារ ឬ ដោយមានការអនុញ្ញាតពីខ្លួន ត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌទី ១ ខាងលើ ។

មន្ត្រីរាជការដែលប្រព្រឹត្តល្មើស ឬ ធ្វេសប្រហែសដោយចេតនា ក្នុងការបំពេញតួនាទីរបស់ខ្លួនពាក់ព័ន្ធការងារសម្បទាន ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលថែមទៀតស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ៤៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.១០០៧.០២៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត់ ឈន់

លេខ: ៥០១ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០០៧

ឃុន ជិនកេន

សទ្ទានុក្រម

LEXICON

- សាងសង់ អាជីវកម្ម និង ផ្ទេរ ហៅកាត់ "ស.អ.ផ" (Build Operate and Trasnsfer(BOT)) : ស្ថាប័នមានសមត្ថកិច្ច ផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មយកកម្រៃក្នុងរយៈមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។ ផុតរយៈពេលនោះ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈល្អតាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យ ស្ថាប័នមានសមត្ថកិច្ចវិញ ។

- សាងសង់ ជួល និង ផ្ទេរ ហៅកាត់ "ស.ជ.ផ" (Build Lease and Transfer(BLT)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនជួលសំណង់នោះពីស្ថាប័នមានសមត្ថកិច្ចក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យាជួល តាមតំលៃឯកភាពគ្នាដើម្បីធ្វើអាជីវកម្ម ។

ផុតរយៈពេលនោះឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យ ស្ថាប័នមានសមត្ថកិច្ចវិញ ។

- សាងសង់ ផ្ទេរ និង អាជីវកម្ម ហៅកាត់ "ស.ផ.អ" (Build Transfer and Operate(BTO)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយត្រូវផ្ទេរសំណង់នោះមកឱ្យ ស្ថាប័នមានសមត្ថកិច្ចកាន់កាប់វិញ ក្រោយពេលសាងសង់រួច ។ ស្ថាប័នមានសមត្ថកិច្ចប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មលើសំណង់នោះ ក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។

- សាងសង់ ធ្វើម្ចាស់ និង អាជីវកម្ម ហៅកាត់ "ស.ម.អ" (Build Own and Operate(BOO)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់ផ្តល់សិទ្ធិឱ្យឯកជនធ្វើជាកម្មសិទ្ធិករលើសំណង់នោះ ហើយឯកជនធ្វើអាជីវកម្មយកកម្រៃលើសំណង់នោះ សម្រាប់បម្រើឱ្យផលប្រយោជន៍សាធារណៈ ក្រោមលក្ខខណ្ឌដែលមានការព្រមព្រៀងពីភាគីទាំងពីរ និងដែលមានចែងក្នុងកិច្ចសន្យាសម្បទាន ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- **សាងសង់ ធ្វើម្ចាស់ អាជីវកម្ម និង ផ្ទេរ ហៅកាត់ "ស.ម.អ.ផ"** (Build Own Operate and Transfer (BOOT)) : ស្ថាប័នមានសមត្ថកិច្ច ផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់ផ្តាច់ឱ្យឯកជនធ្វើជាកម្មសិទ្ធិករលើសំណង់នោះ ហើយឯកជនជាអ្នកធ្វើអាជីវកម្មយកកម្រៃក្នុងរយៈពេលមួយជាកំណត់ ។ ផុតរយៈពេលកំណត់ ឯកជនត្រូវផ្ទេរនូវសិទ្ធិសិទ្ធិកាន់កាប់និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ ។

- **សាងសង់ សហការ និង ផ្ទេរ ហៅកាត់ "ស.ស.ផ"** (Build Corporate and Transfere(BCT)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការសាងសង់នូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយស្ថាប័នមានសមត្ថកិច្ចនោះ និង ឯកជនសហការគ្នាក្នុងការធ្វើអាជីវកម្ម គ្រប់គ្រង កាន់កាប់ ទទួលចំណេញ-ខាត និងរងនូវហានិភ័យនានា ដែលទាក់ទងនឹងអាជីវកម្មរួមគ្នា ក្នុងរយៈពេលដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។ ផុតរយៈពេលកំណត់ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អតាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ ។

- **ពង្រីក អាជីវកម្ម និងផ្ទេរ ហៅកាត់ "ព.អ.ផ"** (Expand Operate and Transfer(EOT)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើការពង្រីកនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មយកកម្រៃលើទីតាំងពង្រីកនោះ ក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន។ ផុតរយៈពេលនោះ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់នៃទីតាំងពង្រីកដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យ ស្ថាប័នមានសមត្ថកិច្ចវិញ ។

- **ធ្វើទំនើបភាវូបនីយកម្ម អាជីវកម្ម និងផ្ទេរ ហៅកាត់ "ធ.អ.ផ"** (Modernize Operate and Transfer(MOT)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើឱ្យមានភាពទំនើបនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធរួចប្រគល់សិទ្ធិឱ្យឯកជនធ្វើអាជីវកម្មយកកម្រៃលើសំណង់ដែលបានធ្វើឱ្យមានភាពទំនើបនោះក្នុងរយៈមួយដែលបានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។ ផុតរយៈពេលនោះ ឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់នៃសំណង់ដែលមានធ្វើឱ្យមានភាពទំនើប និងមានលក្ខណៈល្អតាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យ ស្ថាប័នមានសមត្ថកិច្ចវិញ ។

- **ទំនើបភាវូបនីយកម្ម ធ្វើម្ចាស់ និង អាជីវកម្ម ហៅកាត់ "ទ.ម.អ"** (Modernize Own and Operate (MOO)) : ស្ថាប័នមានសមត្ថកិច្ចផ្តល់សម្បទានឱ្យទៅឯកជនធ្វើឱ្យមានភាពទំនើបនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធដោយប្រគល់សិទ្ធិឱ្យឯកជនធ្វើជាកម្មសិទ្ធិករលើសំណង់នោះ និងធ្វើអាជីវកម្មយកកម្រៃលើសំណង់សម្រាប់បំរើផលប្រយោជន៍សាធារណៈ ក្រោមលក្ខខណ្ឌដែលមានការឯកភាពគ្នារវាងភាគីទាំងពីរ និង ដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទាន ។

- **ជួលនិង អាជីវកម្មគ្រប់គ្រង ឬ កិច្ចព្រមព្រៀងគ្រប់គ្រង :** ជាកិច្ចសន្យាដែលស្ថាប័នមានសមត្ថកិច្ចយល់ព្រមជួលឱ្យឯកជនធ្វើអាជីវកម្ម នៅលើសំណង់ហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈពេលមួយជាកំណត់ ឬ ស្ថាប័ននោះធ្វើអាជីវកម្មខ្លួនឯង ដោយជួលឯកជនមកគ្រប់គ្រង ឬស្ថាប័នមិនធ្វើអាជីវកម្មលើសំណង់នោះទេ តែបានជួលឯកជនមកធ្វើអាជីវកម្មក្រោមការគ្រប់គ្រងរបស់ស្ថាប័នមានសមត្ថកិច្ច ដោយផ្តល់ថ្លៃឈ្នួលតាមការព្រមព្រៀងឯកភាព ដើម្បីបំរើផលប្រយោជន៍សាធារណៈ។

ការជួលខាងលើនេះ អនុវត្តសម្រាប់តែប្រភេទគម្រោងសម្បទាន ដែលមានចែងនៅក្នុងអនុក្រឹត្យប៉ុណ្ណោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៤៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក គីម អ៊ីមយ៉ូ (KIM IMPYO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៦៣ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា គីម អរុណ (KIM AK ROUN) ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧១០.៥១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៧

ច.ល
ឆ្នាំ២០០៧

ព្រះរាជក្រឹត្យ

នស / រកត / ១០០៧ / ៥១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក លាវ ម៉ានកាម (LAU MAN KAM) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៤០ នៅខេត្តហ្វ៊ូជៀន ប្រទេសចិន ដោយប្តូរឈ្មោះជា លាវ យ៉ុងឈៀន (LAU YUNG CHIN) ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១០.៥៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៧

៥៦ច.ល
ចម្លងចែក
ខែ ឆ្នាំ២០០៧
រាជរដ្ឋាភិបាល
ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៥១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា .

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក ម៉ែតស្យូ រ៉ែនដល (MATTHEW NICHOLAS RENDALL). ជនជាតិអូស្ត្រាលី សញ្ជាតិអូស្ត្រាលី កើតថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៦៤ នៅចក្រភពអង់គ្លេស។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១០.៥៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៧

លេខ: ៤ ៧៦៦.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

នស/រកត/១០០៧/៩២៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ :

១	លោកវរសេនីយ៍ឯក	ហួន	ចន្ទកក្កដា	អត្តលេខ	៩៥៩២៥
២	លោកវរសេនីយ៍ឯក	ជុំ	សំណាង	អត្តលេខ	០៥៥៦
៣	លោកវរសេនីយ៍ឯក	អាត	សុមនា	អត្តលេខ	០១៩៦០
៤	លោកវរសេនីយ៍ឯក	ហ៊ីម	សុធារិទ្ធ	អត្តលេខ	០២២២១
៥	លោកវរសេនីយ៍ឯក	យស់	ភូមិរា	អត្តលេខ	០៧៥៩
៦	លោកវរសេនីយ៍ឯក	អ៊ុំ	សំបូរ	អត្តលេខ	០៨០៨
៧	លោកវរសេនីយ៍ឯក	អ៊ុន	ចន្ថា	អត្តលេខ	២០៤១៣
៨	លោកវរសេនីយ៍ឯក	អាយ	ប៊ុណ្ណា	អត្តលេខ	០៩៣៩៣
៩	លោកវរសេនីយ៍ឯក	គិន	ឡាយ	អត្តលេខ	០៦២១
១០	លោកវរសេនីយ៍ឯក	ឃី	សាមឿន	អត្តលេខ	០៦៨០
១១	លោកវរសេនីយ៍ឯក	យ៉ុង	សំខាន់	អត្តលេខ	០១៦៧៣
១២	លោកវរសេនីយ៍ឯក	ខួត	វុន	អត្តលេខ	០៥២១៧

ROYAUME DU CAMBODGE

១៣	លោកវរសេនីយ៍ឯក	ជា	គឹមហ៊ន	អត្តលេខ	៣០៦០៩
១៤	លោកវរសេនីយ៍ឯក	ង៉ិល	វណ្ណធឿន	អត្តលេខ	០១០២៧
១៥	លោកវរសេនីយ៍ឯក	សិទ្ធ	ប៊ុនធី	អត្តលេខ	០១១៧៧
១៦	លោកវរសេនីយ៍ឯក	សាន	តាំងស៊ីធឿន	អត្តលេខ	០៩៤៩៩
១៧	លោកវរសេនីយ៍ឯក	គឹម	យីដេត	អត្តលេខ	០២៤០៤
១៨	លោកវរសេនីយ៍ឯក	សឿន	ផល្លា	អត្តលេខ	០៤៤៤៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកត.១០០៧.៥៥៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៧

លេខ: ៥០៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០០៧

ប្រធានអគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៥២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្សត្តខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក.គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ មាស ០១ គ្រឿង ប្រាក់ ០១ គ្រឿង សំរិទ្ធ ០១ គ្រឿង ចំពោះ ៖

១	លោកឧត្តមសេនីយ៍ត្រី	អ៊ាវ	ចំរើន	០៣៦៤១
២	លោកឧត្តមសេនីយ៍ត្រី	សួន	ផល្លា	០៦០១២
៣	លោកឧត្តមសេនីយ៍ត្រី	កែវ	សុទ្ធា	០៣៩៤
៤	លោកវរសេនីយ៍ឯក	ប៉ោ	ភក្តិ	៩៤៨៦២
៥	លោកវរសេនីយ៍ឯក	យឹម	សារុំ	០២៣៩
៦	លោកស្រីវរសេនីយ៍ឯក	ញៀម	មរកត	៥៥៩៤៥
៧	លោកវរសេនីយ៍ឯក	អ៊ុំ	អុន	៤១៩៤១
៨	លោកវរសេនីយ៍ទោ	ជា	សំបូរ	០៦៧៤៩
៩	លោកវរសេនីយ៍ទោ	សៀប	យូដារ៉ាត់	៩៤០៣៧
១០	លោកវរសេនីយ៍ទោ	កែន	ភុន	០០៩៨
១១	លោកវរសេនីយ៍ទោ	អ៊ូ	ចាន់កុសល	០៥០១១
១២	លោកវរសេនីយ៍ទោ	ជា	សុឃីម	០៥០៤០
១៣	លោកវរសេនីយ៍ទោ	ឈឹម	សុផល	០២៤៥៧
១៤	លោកវរសេនីយ៍ទោ	ឈឹម	ចន្ថា	២០៤៨១
១៥	លោកវរសេនីយ៍ទោ	តឹម	សារិទ្ធ	២០៥១៦
១៦	លោកវរសេនីយ៍ត្រី	ណុប	សម្បត្តិ	០៤៤៤២
១៧	លោកវរសេនីយ៍ត្រី	ឃុន	គេង	០៥៤២០

១៨	លោកវរសេនីយ៍ត្រី	ចាន់	ខូចឿន	០៧៤៨៦
១៩	លោកវរសេនីយ៍ត្រី	សៀង	សុវត្ថិ	៥៤៨៦៦
២០	លោកវរសេនីយ៍ត្រី	ហួន	បញ្ញាវឌ្ឍន៍	០៥៦៩៨
២១	លោកវរសេនីយ៍ត្រី	អ៊ុង	សារុំ	០៣២២២
២២	លោកវរសេនីយ៍ត្រី	ស	រដ្ឋា	៥៤៨៥៧
២៣	លោកវរសេនីយ៍ត្រី	ឈួ	ប៊ុនលី	០៤១១៣
២៤	លោកវរសេនីយ៍ត្រី	ចាន់	ដារ៉ា	០៤៤៤៦
២៥	លោកវរសេនីយ៍ត្រី	ជាន់	ម៉ុង	០២៣៥៩
២៦	លោកវរសេនីយ៍ត្រី	ខាំដេង	នារតី	០៤៥៥៥
២៧	លោកវរសេនីយ៍ត្រី	ជា	សុជាត	០២៩៩៩
២៨	លោកវរសេនីយ៍ត្រី	គង់	សម្បត្តិ	០៣៧៦២
២៩	លោកស្រីវរសេនីយ៍ត្រី	សៀក	អ៊ីម	០៣៤៥៧
៣០	លោកវរសេនីយ៍ត្រី	ជួ	សុគីម	០៧៧៧៨
៣១	កញ្ញាវរសេនីយ៍ត្រី	សាត់	ម៉ី	០៧៨៧៩
៣២	លោកវរសេនីយ៍ត្រី	ហ៊ាន	លី	០៨៩៨៨
៣៣	លោកវរសេនីយ៍ត្រី	អ៊ុក	ញ៉ាន	០៥១១១
៣៤	លោកវរសេនីយ៍ត្រី	ឈឿន	សុចិត្ត	៥៣៨៤៩
៣៥	លោកវរសេនីយ៍ត្រី	លឹម	ហេងលាង	០៥៥៤៥
៣៦	លោកវរសេនីយ៍ត្រី	ប្រាក់	សុជានិត	០៨៥១៧
៣៧	លោកស្រីវរសេនីយ៍ត្រី	ពូច	ផល្លីន	០៣១១៤
៣៨	លោកវរសេនីយ៍ត្រី	ម៉ួន	ធី	០៣៣៣០
៣៩	លោកវរសេនីយ៍ត្រី	អ៊ុក	ចាន់ធា	០៣៤៤៤
៤០	លោកវរសេនីយ៍ត្រី	ពៅ	សារឿន	០៤៥៨១
៤១	លោកវរសេនីយ៍ត្រី	ស	ជេដ្ឋា	០៥៥៥៧
៤២	លោកវរសេនីយ៍ត្រី	ទេព	ស៊ុន	០៧៧៦៩
៤៣	លោកវរសេនីយ៍ត្រី	សំ	សារិទ្ធ	០៨១៨១
៤៤	លោកវរសេនីយ៍ត្រី	សុខុម	សីហា	០៩១៥៥
៤៥	លោកស្រីវរសេនីយ៍ត្រី	ហុង	ប៉ូលីដា	០៩៩៩៩
៤៦	លោកវរសេនីយ៍ត្រី	អ៊ុង	ឃិតឡាយ	១២២៣១
៤៧	លោកវរសេនីយ៍ត្រី	ជុំ	ស៊ីថាមុន្នី	៣៦៧៤៧
៤៨	លោកវរសេនីយ៍ត្រី	ប៊ុត	ផិ	៥៤៨៦៤
៤៩	លោកវរសេនីយ៍ត្រី	ឃឿង	ណាត	៣៤០៣៧
៥០	លោកវរសេនីយ៍ត្រី	លី	ឡាយ៉ារិទ្ធិ	០៧៤៥៨
៥១	លោកវរសេនីយ៍ត្រី	ប្រាក់	សារុធ	០៥១២៩
៥២	លោកវរសេនីយ៍ត្រី	មាស	ទីឃាយុវណ្ណរ៉ុធ	១៦២០៥
៥៣	លោកវរសេនីយ៍ត្រី	ទុំ	ចន្ទី	០៥១១៧

៥៤	លោកវរសេនីយ៍ត្រី	ជា	ស៊ីចាន់	០៩១៤០
៥៥	លោកវរសេនីយ៍ត្រី	ថែម	ជូន	០៩១៣៣
៥៦	លោកស្រីវរសេនីយ៍ត្រី	អ៊ុន	ច័ន្ទធី	៥៥៥៩៧
៥៧	លោកវរសេនីយ៍ត្រី	ហេង	អាន	០៧៥៥០
៥៨	លោកវរសេនីយ៍ត្រី	គុជ	ដានី	០៤៨២២
៥៩	លោកវរសេនីយ៍ត្រី	ស៊ិន	សាគុណ	០៦៩៩៩
៦០	លោកវរសេនីយ៍ត្រី	ចាន់	សារឿន	០៤៨២៥
៦១	លោកវរសេនីយ៍ត្រី	ស៊ុម	សុទ្ធារិទ្ធ	១២៩៥១
៦២	លោកវរសេនីយ៍ត្រី	ឡេង	បូរាណ	០៦០២៤
៦៣	លោកវរសេនីយ៍ត្រី	អ៊ុង	សុវណ្ណ	០៥២៨១
៦៤	លោកវរសេនីយ៍ត្រី	ធឹម	គីង	០៥៨៣៣
៦៥	លោកវរសេនីយ៍ត្រី	ហ៊ីង	ហាន	០៣៨៣១
៦៦	លោកវរសេនីយ៍ត្រី	ហាន់	សាវ៉ែត	៣៣១៣៥
៦៧	លោកវរសេនីយ៍ត្រី	សៀម	សារិទ្ធ	២២១៥២
៦៨	លោកវរសេនីយ៍ត្រី	ចេង	បុញ្ញរិទ្ធ	០៩៨៣៤
៦៩	លោកវរសេនីយ៍ត្រី	អ៊ុម	ពុធទិវា	៥៤២៤៣
៧០	លោកវរសេនីយ៍ត្រី	ណយ	ហឿន	២០៤៦៦
៧១	លោកវរសេនីយ៍ត្រី	ហង្ស	ខហិស្សរ៉ា	២០៤២៣
៧២	លោកវរសេនីយ៍ត្រី	ភុន	សុផល	៥៤៦៧៦
៧៣	លោកវរសេនីយ៍ត្រី	កែន	សុធន	៥៣៧៩៥
៧៤	លោកវរសេនីយ៍ត្រី	សោម	ប្រាថ្នា	៥៤១៨៨
៧៥	លោកវរសេនីយ៍ត្រី	លី	ហុកសេង	០៣៦០៥
៧៦	លោកវរសេនីយ៍ត្រី	អាង	ឧស្សាហ៍	០៣៦០៤
៧៧	លោកវរសេនីយ៍ត្រី	សរ	គឹមអាន	០៩៣៦៩
៧៨	លោកវរសេនីយ៍ត្រី	កួយ	ចាន់ធុល	០៣១៥៩
៧៩	លោកវរសេនីយ៍ត្រី	គឹម	ហុង	០៨៩៩៨
៨០	លោកវរសេនីយ៍ត្រី	ម៉ាត់	អរុណរ៉ា	១២១៥៦
៨១	លោកវរសេនីយ៍ត្រី	ជា	លឹមអៀង	១៥៧៧៧
៨២	លោកវរសេនីយ៍ត្រី	ឡឹក	សុខា	០៨៤៩៧
៨៣	លោកវរសេនីយ៍ត្រី	ពិល	ម៉ារ៉ុង	០៤៧៥២
៨៤	លោកវរសេនីយ៍ត្រី	អោម	ភិរម្យ	១១៨៩១
៨៥	លោកវរសេនីយ៍ត្រី	រស់	សារឹម	០៧៥៥៩
៨៦	លោកវរសេនីយ៍ត្រី	តាំ	អឿន	០៧៤៥០
៨៧	លោកវរសេនីយ៍ត្រី	គន្ធ	មុន្នីនាថ	០៣៨២៦
៨៨	លោកវរសេនីយ៍ត្រី	ចាន់	អូន	០៤៩៦៥
៨៩	លោកវរសេនីយ៍ត្រី	ហាន	សុផល	២៤៤៤៤

UME DU CAMBODGE

៩០	លោកវរសេនីយ៍ត្រី	វិន	សុខា	១០០១០
៩១	លោកវរសេនីយ៍ត្រី	យឹម	សារ៉ាន់	០៧៧៨៨
៩២	លោកវរសេនីយ៍ត្រី	ខាំវែង	ច័ន្ទវត្ថិ	០៣០៣៣
៩៣	លោកវរសេនីយ៍ត្រី	ពូច	ប៊ុនថាន	០៤៧៦១
៩៤	លោកវរសេនីយ៍ត្រី	សូ	សារិម	០៤៨០៧
៩៥	លោកវរសេនីយ៍ត្រី	វ៉ែត	ច័ន្ទណារ៉ា	០៥៧២៧
៩៦	លោកវរសេនីយ៍ត្រី	ចាន់	សារិន	០៣០១០
៩៧	លោកវរសេនីយ៍ត្រី	ចាប	សុងហាក់	០៥៦៧១
៩៨	លោកវរសេនីយ៍ត្រី	ម៉ា	វៀម	០៧២៣៧
៩៩	លោកវរសេនីយ៍ត្រី	អៀ	សុផល	១២១៥៥
១០០	លោកវរសេនីយ៍ត្រី	សម្បត្តិ	មុន្នីរ័ត្ន	១៤៤៥៥
១០១	លោកវរសេនីយ៍ត្រី	ហេង	នី	១២១៥៤
១០២	លោកវរសេនីយ៍ត្រី	គង់	ឡុងឌី	១២១៥៩
១០៣	លោកវរសេនីយ៍ត្រី	ម៉ម	យ៉ុយ	០៤៧៤៣
១០៤	លោកវរសេនីយ៍ត្រី	ឌិន	ដារ៉ូ	១២១៣៦
១០៥	លោកវរសេនីយ៍ត្រី	អ៊ុម	វុត	០៤៧៤៧
មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧. សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណ អាកាសយានដ្ឋានអន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រ ទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់ អាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលមាត្រា នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយាន អន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះ នៅពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ ដែលមានសមាសភាព ដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២-ឯកឧត្តម **ញឹម វណ្ណដា**	ទេសរដ្ឋមន្ត្រី អនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	អនុប្រធាន
៣-ឯកឧត្តម **ម៉ៅ ហាសវណ្ណាល់**	រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	អនុប្រធាន
៤-ឯកឧត្តម **ឯម សំអាន**	រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ	អនុប្រធាន
៥-ឯកឧត្តម **ឱម យ៉ិនទៀង**	ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា	អនុប្រធាន
៦-ឯកឧត្តម **ហ៊ុន សម**	រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧-ឯកឧត្តម **ហេង តៃគ្រី**	រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល នាយកមន្ទីរពេទ្យកាល់ម៉ែត	សមាជិក
៨-ឯកឧត្តម **នឹម ចន្ទតារា**	អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៩-ឯកឧត្តម **កែវ សាផល**	អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
១០-ឯកឧត្តមឧត្តមសេនីយ៍ **ផាន់ ខូន**	អនុរដ្ឋលេខាធិការ នៃក្រសួងការពារជាតិ	សមាជិក
១១-ឯកឧត្តមឧត្តមសេនីយ៍ **សៅ សុខា**	មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១២-ឯកឧត្តមឧត្តមសេនីយ៍ **សឹង សំណាង**	មេបញ្ជាការកងទ័ពជើងអាកាស	សមាជិក
១៣-ឯកឧត្តមឧត្តមសេនីយ៍ **យូ ស៊ីនឡុង**	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
១៤-ឯកឧត្តមអភិបាលរាជធានីភ្នំពេញ		សមាជិក
១៥-ឯកឧត្តមអភិបាលខេត្តសៀមរាប		សមាជិក
១៦-ឯកឧត្តមអភិបាលក្រុងព្រះសីហនុ		សមាជិក

១៧-ឯកឧត្តមឧត្តមសេនីយ៍ ម៉ៅ សុផាន់ មេបញ្ជាការកងពលតូចលេខ ៧០ សមាជិក

១៨-ឯកឧត្តមឧត្តមសេនីយ៍ ចាប ភក្តី មេបញ្ជាការកងពលតូចដំក្រយោងលេខ ៩១១ សមាជិក

១៩- ឯកឧត្តម ម៉ក់ ពេជ្ររិទ្ធ ប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

២០-លោកឧត្តមសេនីយ៍ ថោង លឹម ប្រធាននាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

២១-លោក ខៀវ សំអាន ប្រធានការិយាល័យគយ និងរដ្ឋាករ ប្រចាំអាកាសយានដ្ឋានអន្តរជាតិ សមាជិក

២២-លោកឧត្តមសេនីយ៍ ម៉ិន នី នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក

២៣-លោក ម៉ិន រដ្ឋា នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប សមាជិក

២៤-លោក ហ៊ិន ឈឿន នាយកអាកាសយានដ្ឋានអន្តរជាតិ ក្រុងព្រះសីហនុ សមាជិក

២៥-លោកអគ្គនាយកក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

២៦-លោកអគ្គនាយកក្រុមហ៊ុនសេវាកម្មគ្រប់គ្រងចរាចរដែនអាកាស នៃព្រះរាជាណាចក្រកម្ពុជា សមាជិក

ប្រការ ២ : គណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះ ពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ច :

-ដឹកនាំការងារធ្វើលំហាត់សមយុទ្ធជួយសង្គ្រោះយន្តហោះ និងអ្នកដំណើរតាមការកំណត់គ្រោងទុក

-ត្រៀមរៀបចំកម្លាំង សម្ភារៈ និងឧបករណ៍ ឱ្យបានគ្រប់គ្រាន់ក្នុងការអនុវត្តការងារជួយសង្គ្រោះ មុនពេលរៀបចំសមយុទ្ធ ក្នុងពេលកំពុងដំណើរការសមយុទ្ធ ក្រោយពេលការងារសមយុទ្ធត្រូវបានបញ្ចប់ និងពេលមានគ្រោះថ្នាក់យន្តហោះជាក់ស្តែង ឬ ជួបឧបទ្ទវហេតុផ្សេងៗ ដោយចៃដន្យកើតឡើងនៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ

-សហការជាមួយក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជំរុញឱ្យការងាររុករក ជួយសង្គ្រោះយន្តហោះ និងអ្នកដំណើរ នៅពេលជួបឧបទ្ទវហេតុខាងលើ

-ធ្វើរបាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ក្រោយពេលធ្វើលំហាត់សមយុទ្ធ ឬក្រោយពេលសង្គ្រោះយន្តហោះ និងអ្នកដំណើរនៅពេលជួបឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះជាក់ស្តែង ។

ប្រការ ៣ : គណៈកម្មាធិការសម្រាប់សម្របសម្រួលការងាររៀបចំលំហាត់សមយុទ្ធ និងជួយសង្គ្រោះពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះ នៅក្នុង និងក្បែរបរិវេណអាកាសយានដ្ឋានអន្តរជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ដោយប្រើប្រាស់មន្ត្រីទាំងអស់របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាដែលមានស្រាប់ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : រាល់ការចំណាយសម្រាប់រៀបចំលំហាត់សមយុទ្ធ ជាបន្ទុករបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ និងក្រុមហ៊ុនសេវាកម្មគ្រប់គ្រងចរាចរដែនអាកាស នៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះការចំណាយសង្គ្រោះ ពេលមានឧបទ្ទវហេតុគ្រោះថ្នាក់យន្តហោះជាក់ស្តែង ជាបន្ទុករបស់រាជរដ្ឋាភិបាល ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ១៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

ដូចប្រការ ៥

រាជកិច្ច

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥៧...ស.សរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

ស ម្រេ ច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ** ដែលមានសមាសភាពដូចខាងក្រោម :

១-លោក	**ហ៊ុន ម៉ាណែត**	ប្រធាន
២-លោក	**សុខ ពុទ្ធិវុធ**	អនុប្រធានទី១
៣-ឯកឧត្តម	**ស៊ាន ចូរ៉ាត**	អនុប្រធានអចិន្ត្រៃយ៍
៤-លោក	**ជា ពិសី**	សមាជិក
៥-លោក	**ជួន ជីវិន**	សមាជិក
៦-លោកស្រី	**មាស វិចិត្រ**	សមាជិក

ប្រការ ២ : គណៈកម្មាធិការអាហារូបករណ៍សិស្ស-និស្សិតក្រីក្រ មានភារកិច្ចដូចតទៅ :

-អំពាវនាវគ្រឹះស្ថានឧត្តមសិក្សានានា នៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីរកអាហារូបករណ៍

-គ្រប់គ្រង និងបែងចែកដល់សិស្ស-និស្សិតក្រីក្រ នូវអាហារូបករណ៍ ដែលគ្រឹះស្ថានឧត្តមសិក្សានានា ផ្តល់ជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ**

-ធ្វើការពិនិត្យបណ្តាសិស្ស-និស្សិតអាហារូបករណ៍ដែលគណៈកម្មាធិការបានផ្តល់ជូន

-ធ្វើរបាយការណ៍ជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រការ ៣ : នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសាមីជន ដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ..១០៤៩..ឧរថ..កឧ- ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦៩៥/០៧ គ.វ.ក ចុះថ្ងៃទី២៨.០៩.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូ ហាន់សែ ចុះថ្ងៃទី១១.០៩.២០០៧

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូ ហាន់សែ (CAMBO HANSAE CO., LTD.) តំណាងដោយ លោក KIM SANGRYUR សញ្ជាតិកូរ៉េ អាយុ៣៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ SC1905643 ចុះថ្ងៃទី៣០.០៥.២០០៦ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់"ដែលមានឈ្មោះថា"ខេមបូ ហាន់សែ (CAMBO HANSAE)" មានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លៃ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone : 855-23-211141. Fax : 855-23-428263

<u>ប្រការ២:</u> មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុន រយៈពេល១៥ថ្ងៃ និង ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលនឹងតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៣:</u> រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤:</u> ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

<u>ប្រការ៥:</u> ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦:</u> ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

<u>ប្រការ៧:</u> ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

<u>ប្រការ៨:</u> ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

<u>ប្រការ៩:</u> ប្រកាសលេខ ២០១ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២៨.០៣.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន " ខេមបូ ហាន់សូល " (CAMBO HANSOLL CO., LTD.) ត្រូវចាត់ទុក ជានិរាករណ៍ ។

<u>ប្រការ១០:</u> អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ខេមបូ ហាន់សែ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

<u>ប្រការ១១:</u> ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

<u>ចម្លងជូន :</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ១០ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១០៥៩ ឧ.ស.ម.ស.ក.ឧ-ប្រក .

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៨៣៨/០៧ ត.វ.ក ចុះថ្ងៃទី០៥.១០.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើ របស់ក្រុមហ៊ុន ដាន់ស៍ ស៊ីបផ្លាយ (ខេមបូឌា) លីមីធីត ចុះថ្ងៃទី០១.១០.២០០៧

សម្រេច

<u>ប្រការ១</u>: អនុញ្ញាតឱ្យក្រុមហ៊ុន ដានស៍ ស៊ីបផ្លាយ (ខេមបូឌា) លីមីធីត (DANCE SUPPLY (CAMBODIA) LIMITED តំណាងដោយ លោក SANTI SAENGNAKORN សញ្ជាតិថៃ អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ L694522 ចុះថ្ងៃទី០៩.០៣.២០០៦ បង្កើតរោងចក្រ "ផលិតស្បែកជើងគ្រប់ប្រភេទ" ដែលមានឈ្មោះថា " ដានស៍ ស៊ីបផ្លាយ (ខេមបូឌា) លីមីធីត (DANCE SUPPLY (CAMBODIA) LIMITED)" ដែលមានទីតាំងស្ថិតនៅ អាគារលេខ10 ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតស្បែកជើងគ្រប់ប្រភេទ" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ដានស៍ ស៊ីបផ្លាយ (ខេមបូឌា) លីមីធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៤៣ ពណ.នគក

ភ្នំពេញថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ២០០៧

ឧបសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **ធី ណាវី ខេមបូ ឌីវេឡុបមេន**	
	TY NAVY CAMBO DEVELOPMENT Co., Ltd.	
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 9737/07P ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០៧	
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត	
២- អភិបាលក្រុមហ៊ុន	: លោក ទន់ ស៊ីនួន	ប្រធានក្រុមប្រឹក្សាភិបាល
	លោក LE HUNG MY	អភិបាល
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ៤០.០០០.០០០ រៀល	
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ២៤២ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។	
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ	

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក [illegible] និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារ [illegible]
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ទីស្តីការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៤៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: ប្រាយ៉ា ខូ អិលធីឌី PRAGYA CO.,LTD.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 3479/07E ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោក KARTIK SAHAY ប្រធានក្រុមប្រឹក្សាភិបាល លោកស្រី PHAM HOANG VIET HONG អភិបាល
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ២០ CEo ផ្លូវលេខ ១៧៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសឱសថ សំភារៈបរិក្ខារពេទ្យ គ្រឿងសំអាង វត្ថុធាតុដើមសំរាប់ផលិត ឱសថ វត្ថុធាតុគីមីសំរាប់បំរើអោយវិស័យឧស្សាហកម្ម គ្រឿងឧបភោគបរិភោគគ្រប់ប្រភេទ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន មហាវិទ្យាល័យ សកលវិទ្យាល័យ និងវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈគ្រប់ប្រភេទ ពិសេសវិស័យសុខាភិបាល -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងធានារ៉ាប់រង -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវារកការងារជូនពលករធ្វើការនៅក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត និងវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញ និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

រដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
សម្រាប់ព

គឹម_ស៊ីថៈ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១០៤៦ ពណ.នគក

ភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **និល ពៅ**
NIL POV Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9735/07P ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **និល សុខ្មាច័ន្ទ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិវត្តគរ ឃុំវត្តគរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងផ្ញើតាមប្រៃសណីយ៍
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តបាត់ដំបង
- មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៥៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៧

សេចក្តីសម្រេច រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: ហៀប-សេង ហ៊ីន ខូ អិលធីឌី HIAP - SENG HIN Co., Ltd.		
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 9747/07P ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៧		
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត		
២- អភិបាលក្រុមហ៊ុន	: លោក ឃូ ធីរ		ប្រធានក្រុមប្រឹក្សាភិបាល
	លោក សុខ សុភា		អភិបាល
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល		
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ១៧៨ Eo ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ។		
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ		

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត និងវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ... ទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ និង...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្រុបទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- [illegible]
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៥៦ ពណ.នតក

ភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : ស៊ី ស៊ី វីន
C C WINN Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3485/07E ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក PHAM HONG SON
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្លូវជាតិលេខ ១ ភូមិបាវិតកណ្តាល ឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។
៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវា[illegible]ចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្មកែច្នៃកសិផល ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ៕

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា

ប៉ាន់ ស៊ីធារ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តស្វាយរៀង
- មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៦០ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មិ.ស ឆ្នាំ ២០០៧

នេសររដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សេន ហ្វារម៉ា អិលធីឌី**

SEN PHARMA LTD

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9718/07P ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៧

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **អ៊ិង អេងហុង** ប្រធានក្រុមប្រឹក្សាភិបាល

លោក NICOLLE Daniel Paul - Eugène អភិបាល

លោក **សុខ ខាន់ារ៉ាន់** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១ ផ្លូវលេខ ១៥០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ សំភារៈបរិក្ខារ និងថ្នាំពេទ្យ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម ដីធ្លី ផ្ទះសំបែង

-សេវាយកកិរិយជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់ធនធានមនុស្ស

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត សាលល្ខោនសិល្បៈ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

៦- ចិរវេលា ៩៩ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៥

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គីម_ស៊ីថន

<u>ចំលងជូន</u>

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៦៣ ពណ.នតក

ភ្នំពេញថ្ងៃទី ១៤ ខែ ៦ ៨ ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ញូ ហ្វ័រម៉ូសា ត្រេឌីង**
NEW FORMOSA TRADING Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3488/07E ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី LI, MEI -YI aka CHRISTINE LI

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ

-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកតំរែជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកតំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចាម_ប្រសិទ្ធ

<u>**ចំលងជូន**</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ ✓
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៣៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **ផេនថ៍ ខនស្ត្រាក់សិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** **PAINT CONSTRUCTION (CAMBODIA) Pte.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 3486/07E ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៧
មានទម្រង់ទ្រាយជា	: សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោក **LAKOY HAYN SAREY**
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ៧២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ 69Eo វិថីព្រះមុនីវ៉េត សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេ -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៥៥ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

...ពាណិជ្ជកម្ម

...ជិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ